# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៤២ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតគណៈកម្មាធិការសំរុះសំរួល**

**ទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ**

*****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

**សំរេច**

**មាត្រា ១**: បង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍មួយ មានឈ្មោះថា :

គណៈកម្មាធិការសំរុះសំរួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ ។

**មាត្រា ២**: សមាសភាពគណៈកម្មាធិការនេះ រួមមាន :

| | |
|---|---|
| ១-រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ | ប្រធាន |
| ២-សហអនុរដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣-តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៤-តំណាងក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន | សមាជិក |
| ៥-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦-តំណាងក្រសួងអប់រំយុវជន និងកីឡា | សមាជិក |
| ៧-មន្ត្រីនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ០១រូប | លេខាធិការ |

**មាត្រា ៣**: គណៈកម្មាធិការនេះ មានភារកិច្ចសំរុះសំរួលទំនាស់ពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការ ដូចជា ត្រួតពិនិត្យកិច្ចសន្យាទាំងឡាយក្នុងផែនការនៃការបណ្តុះបណ្តាល ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ការឡើងឋានន្តរសក្តិ ឬ ការដាក់វិន័យមន្ត្រីរាជការ ការផ្លាស់ប្តូរ ការផ្តល់ប្រាក់បំណាច់ផ្សេងៗ ។ល។

**មាត្រា ៤**: គណៈកម្មាធិការនេះ មានសិទ្ធិអញ្ជើញតំណាងស្ថាប័នដែលមានការពាក់ព័ន្ធនិងសាមីខ្លួនមកបំភ្លឺក្នុងករណីចាំបាច់ ។

**មាត្រា ៥**: ការប្រព្រឹត្តិរបស់គណៈកម្មាធិការនេះ អាស្រ័យដោយប្រធានគណៈកម្មាធិការជាអ្នកកំណត់ណែនាំ ។ គណៈកម្មាធិការនេះ មានទីតាំងនៅរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង មានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ៦**: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម អស់លោកក្នុងមាត្រា ២ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៩៥

**នាយករដ្ឋមន្ត្រី ១** **នាយករដ្ឋមន្ត្រី ២**

**នរោត្តម រណប្ញទ្ធិ** **ហ៊ុន សែន**

<u>ចម្លងជូន</u> ៖

-ខុទ្ទកាល័យព្រះមហាក្សត្រ

- អគ្គលេខាធិការដ្ឋានរដ្ឋសភា

- ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

- ដូចមាត្រា ៦

- ឯកសារ-កាលប្បវត្តិ